ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌសើរើ　　　　　　**នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ០១ ស.រ　　　　　　**តុលាការកំពូល**

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៣

សាលដីកា　　　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៤ ខែ ឧសភា

លេខ : ៣១　　　　　　ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គឹមសាន ចៅក្រម

៤- លោក គង់ ភិរុន ចៅក្រម

៥- លោក ស៊ិន ឌឹម ចៅក្រម

៦- លោក យស់ សូខឿន ចៅក្រម

៧- លោក សោម សិរិវឌ្ឍ ចៅក្រម

៨- លោក ប៉ែន សារឿន ចៅក្រម-របាយការណ៍

៩- លោក ម៉ុង មុន្នីចរិយា ចៅក្រម

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសើរើ ពីសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ២៥ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការកំពូល និង សំណុំរឿងព្រហ្មទណ្ឌ សើរើលេខ០១ ស.រ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

***ចោទ*** : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិស្តោកខ្លែង ឃុំជីផដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ ។

១-ចណ្តិតឈ្មោះចាន់ សុគន្ធា ហៅគម (ជាម្ចាស់បណ្តឹងសើរើ) ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន កើត និង ទីលំនៅសព្វថ្ងៃភូមិស្តោកខ្លែង ឃុំជីផដ្ឋ ស្រុកកៀនស្វាយ

ខេត្តកណ្តាល ឪពុកឈ្មោះចាន់ យ៉េត "រ" ម្តាយឈ្មោះមាស សា "រ" ប្តីឈ្មោះជុំ សុជាន់ណារ៉ា ។ (នៅក្រៅឃុំ)

២-ទណ្ឌិតឈ្មោះចាន់ សុគន្ធី ហៅម៉ាប់ (ជាម្ចាស់បណ្តឹងសើរើ) ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន កើត និង ទីលំនៅសព្វថ្ងៃភូមិស្តៅកន្ទេង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះចាន់ យ៉េត "រ" ម្តាយឈ្មោះមាស សា "រ" នៅលីវ ។ (នៅក្រៅឃុំ)

-មេធាវី : គ្មាន

-ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយាវ សុគ្គា ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិស្តៅកន្ទេង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្តីឈ្មោះ ហួត គន្ធា គ្មានកូន ។

-មេធាវី : គ្មាន

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៧ ,១៨ ខែសីហា ឆ្នាំ១៩៩៤របស់ឈ្មោះយាវ សុគ្គា បានប្តឹងពីឈ្មោះ ចាន់ សុគន្ធី ,ចាន់ សុគន្ធា ,ចាន់ យ៉េត និង ជុំ សុជាន់ណារ៉ា ដោយអ្នកទាំងនេះ បានជេរជៀមដាមខ្លួន និង នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ វេលាម៉ោង៩ និង ៣០នាទី ទាំងបួននាក់នេះបានសំរុកចូលផ្ទះខ្លួន ហើយ ព្រួតវាយខ្លួន ដែលខ្លួននៅតែម្នាក់ឯង ពេលនោះខ្លួនក៏ស្រែកឱ្យគេជួយ ។ ពួកទាំងបួននាក់ខាងលើបានវាយ ខ្លួនឱ្យរលូតកូន ដែលខ្លួនកំពុងមានផ្ទៃពោះមួយខែទៅហើយ និង បណ្តាលឱ្យបាត់ខ្សែក២ជី កងដៃចំនួន៣ ផ្លាទីន ក្រវិលមួយចំហៀង ៥ហ៊ុន ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកណ្តាលថា : មានពិរុទ្ធគ្រប់ គ្រាន់លើជនជាប់ចោទទាំង៤នាក់នេះ គឺឈ្មោះចាន់ សុគន្ធា ,ចាន់ សុគន្ធី ,ចាន់ យ៉េត និង ជុំ សុជាន់ណារ៉ា ដែលបានវាយធ្វើឱ្យរបួសស្នាមលើជនរងគ្រោះឈ្មោះយាវ សុគ្គា កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ ប្រាកដមែន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៧"គ" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្ត កណ្តាល ដែលបានសំរេច :

**I-ផ្តន្ទាទោស**

១-ជនជាប់ចោទឈ្មោះចាន់ សុគន្ធា ហៅ "គម" ក្រៅឃុំ "ដាក់ពន្ធនាគារ កំនត់៨ខែ តែទោសនេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

២-ជនជាប់ចោទឈ្មោះចាន់ សុគន្ធី ហៅ "ម៉ាប់" "ក្រៅឃុំ" ដាក់ពន្ធនាគារ កំនត់៨ខែ តែទោសនេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

៣-ជនជាប់ចោទឈ្មោះចាន់ យ៉េត "ក្រៅឃុំ" ដាក់ពន្ធនាគារ កំនត់៨ខែ តែទោស នេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

៤-ជនជាប់ចោទឈ្មោះជុំ សុជាន់ណារ៉ា "ក្រៅឃុំ"ដាក់ពន្ធនាគារ កំនត់៨ខែ តែទោស នេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

ពីបទ : រួមគ្នាបង្ករបួសស្នាមដោយចេតនា លើរូបរាង យាវ សុគ្គា បណ្តាលឱ្យរលូតកូន កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ ប្រព្រឹត្តនៅភូមិស្តៅកន្ទែង ឃុំជីផង្ស ស្រុកក្បៀនស្វាយ ខេត្តកណ្តាល។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១ វាក្យខ័ណ្ឌ២ , ៦៨ និង ៧០ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**II**-បង្គាប់ឱ្យនាង ចាន់ សុគន្ធា ហៅ"គម" ,ចាន់ សុគន្ធី ហៅ "ម៉ាប់" ចាន់ យ៉េត និង ជុំ សុជាន់-ណាវ៉ា រួមគ្នាសងសំណងការព្យាបាល និង ជម្ងឺចិត្តជាប្រាក់សរុបចំនួន២,៥ លានរៀល ។ សំណងលើសពីនេះបដិសេធ ទៅជនរងគ្រោះឈ្មោះនាង យាវ សុគ្គា ក្នុងករណីទណ្ឌិតខាងលើ ពុំមានទ្រព្យសម្បត្តិសង ធនទណ្ឌគ្រប់ចំនួនទេនោះ ត្រូវដាក់គុកបង្ខំដល់រូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

**III**-វត្ថុតាង

- ដំបងឬស្សី ប្រវែង៦ទឹក
- ស្បែកជើងមនុស្សស្រីមួយចំហៀង លេខ៤១ ត្រូវរឹបអូសបំផ្លាញចោល ។

**IV**-សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខជនរងគ្រោះ បើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ និង កំបាំងមុខជនជាប់ចោទឈ្មោះចាន់ សុគន្ធា ,ចាន់ សុគន្ធី ហៅ "ម៉ាប់" ,ចាន់ យ៉េត និង ជុំ សុជាន់ណាវ៉ា ទុកសិទ្ធិឱ្យប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និង ប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ របស់ឈ្មោះយាវ សុគ្គា ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៧"គ" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចទីII នៃសាលក្រម ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថាៈ តម្កល់សាលក្រម ព្រហ្មទណ្ឌលេខ៧"គ" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ របស់ឈ្មោះយាវ សុគ្គា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោទ ដោយទាស់ខុសនឹងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៧ របស់ជនជាប់ចោទទាំងបួននាក់ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៧"គ" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះចាន់ សុគន្ធី ,ចាន់ សុគន្ធា ចាន់ យ៉េត និង ជុំ សុជាន់ណារ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៣៤"ខ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០១ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងទាស់លេខ១៦ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធ ដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់សាលា-ឧទ្ធរណ៍ ទុកជាបានការ ដោយគ្រាន់កែប្រែ និង សំរេចបន្ថែមថា ឱ្យឈ្មោះចាន់ យ៉េត រួចពីបទចោទ ។

សាលដីកានេះជំនុំជំរះ និង ប្រកាសសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ និង ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខ២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៧៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះជុំ សុជាន់ណារ៉ា ចាន់ សុគន្ធា និង ចាន់ សុគន្ធី ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២៣៤"ខ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះជុំ សុជាន់ណារ៉ា ,ចាន់ សុគន្ធា ,ចាន់ សុគន្ធី ពិតជាបង្ករបួសស្នាមដោយចេតនាកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៤ មែន ។ សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៣៤ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៥ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣របស់តុលាការកំពូល ដែលបានសំរេច :

១-ទទួលបណ្តឹងសាទុក្ខលេខ០៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ ជុំ-សុជាន់ណារ៉ា ,ចាន់ សុគន្ធា និង ចាន់ សុគន្ធី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៣៤"ខ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះជុំ សុជាន់ណារ៉ា ដែលត្រូវទុកជាមោឃៈ ។

៣-សំរេចឱ្យឈ្មោះជុំ សុជាន់ណារ៉ា រួចខ្លួនពីបទចោទ ។

៤-សាលដីកានេះប្រកាសជាសវនាការ ជាសាធារណៈនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៣។

-បានឃើញបណ្តឹងសើរើ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះចាន់ សុគន្ធា និង ចាន់-សុគន្ធា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ២៥ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

-បានឃើញលិខិតបំភ្លឺរបស់សាក្សីឈ្មោះគង់ ហួរ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : បណ្តឹងសើរើរបស់ទណ្ឌិតទាំងពីរ ពុំនាំមកនូវភស្តុតាងថ្មី មិនត្រឹមត្រូវតាមមាត្រា២៣០ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌឡើយ ហើយសាក្សីដែលនាំមកជូននោះជាបទប្អូនជីដូនមួយនឹងទណ្ឌិតទាំងពីរនាក់នេះ ហើយក៏ពុំមានវត្តមាននៅកន្លែងកើតហេតុ ដែរ ។

ដូច្នេះសូមតុលាការពិនិត្យ និង សំរេចតាមច្បាប់ ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង ពាក្យបណ្តឹងសើរើរបស់ទណ្ឌិត នៅពេលជំនុំជំរះ ។

-បានស្តាប់ក្រឡាបញ្ជីអានពាក្យបំភ្លឺរបស់សាក្សី នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : គ្មានយោបល់បន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ពាក្យសុំសើរើរបស់ទណ្ឌិត

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសើរើចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣របស់ ចាន់ សុគន្ធា និងចាន់ សុគន្ធី ធ្វើឡើងត្រឹមត្រូវតាមទំរង់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា២២៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការលើកឡើងរបស់ទណ្ឌិត ចាន់ សុគន្ធា និង ចាន់ សុគន្ធី ក្នុងពាក្យបណ្តឹងសើរើចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ថា ពួកខ្លួនមានសាក្សីថ្មី ដែលអាចឆ្លើយបញ្ជាក់ដោះបន្ទុកបានថា ពួកខ្លួនពិតជាពុំមានកំហុសក្នុងបទល្មើសបង្ករបួសស្នាមទៅលើជនរងគ្រោះឈ្មោះយាវ សុផ្លា ទេ ដោយសំអាងទៅលើភស្តុតាងជូនមកតុលាការកំពូលនោះ ពុំមានលក្ខណៈគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា២៣០ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឡើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-លើកបណ្តឹងសើរើ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ទណ្ឌិត ចាន់ សុគន្ធា និង ចាន់ សុគន្ធី ចោលជាអសារបង់ ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ ។